ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០២៨៣.រ៉ែ.ឋាប.ប្រក

# ប្រកាស
# ស្ដីពី
# នីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជី ក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់ និងសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់និងប្ដូរដល់យានយន្ត

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាល លេខ ០៧.សរណន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ស្ដីពីវិធានការគ្រប់គ្រងអាជីវកម្មចែកចាយផលិតផលតេលាសិលា



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែនិងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់នីតិវិធីចេញលិខិតអនុញ្ញាតសន្និធិឬអាជ្ញាបណ្ណសន្និធិឧស្ម័នអិលភីជី (ហ្គាស) ក្នុងកំប៉ុងនិង/ឬធុងដែលមានចំណុះចាប់ពី៤៨ គីឡូក្រាមចុះក្រោមដើម្បីលក់ និងលិខិតអនុញ្ញាតសន្និធិ ឬអាជ្ញាបណ្ណសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់និងប្តូរដល់យានយន្ត ឱ្យអាជីវករឬក្រុមហ៊ុនដែលមានបំណងបើកទីតាំងលក់ឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុងឬបើកទីតាំងលក់ និងប្តូរប្រេងរំអិលក្នុងកំប៉ុងឬធុង ឱ្យបានទាន់ពេលវេលាប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវស្របតាមមាត្រា ៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាតនិងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ២.-**

កំណត់និយមន័យវាក្យស័ព្ទបច្ចេកទេសប្រើប្រាស់ក្នុងប្រកាសនេះ ដូចតទៅ៖

**បុគ្គល** សំដៅដល់ រូបវន្តបុគ្គល ឬនីតិបុគ្គល។

**ឧស្ម័នអិលភីជី** សំដៅដល់ឧស្ម័នប្រេងកាតដែលត្រូវបានពង្រាវ (Liquefied Petroleum Gas, LPG)។

**ប្រេងរំអិល** សំដៅដល់ផលិតផលប្រេងកាតលាយជាមួយសារធាតុជំនួយ ដើម្បីបានវត្ថុធាតុរំអិល សម្រាប់ប្រើនៅចន្លោះរវាងផ្ទៃធ្វើចលនាប៉ះគ្នាពីរ ឬលើផ្ទៃរំកិល ក្នុងការជួយកាត់បន្ថយ



៤

ភាពធន់នឹងការកកិតរវាងផ្ទៃទាំងពីរ។

## ជំពូកទី ២
## ការដាក់ពាក្យស្នើសុំ

**ប្រការ៣.-**

បុគ្គលដែលមានបំណងលក់ឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុង ឬដែលមានបំណងលក់និងប្តូរប្រេងរំអិលក្នុងកំប៉ុងឬធុង ដែលមានមធ្យោបាយផ្ទុកនិងកម្រិតសន្និធិជាក់ស្តែងសរុបដូចខាងក្រោម **ត្រូវមានលិខិតអនុញ្ញាតសន្និធិពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ** ដែលទីតាំងអាជីវកម្មនោះស្ថិតនៅ៖

ក- ចំពោះឧស្ម័នអិលភីជី ដែល៖

- ប្រើកំប៉ុង ឬ ធុងដែលមានចំណុះឧស្ម័នអិលភីជីចាប់ពី ៤៥ គីឡូក្រាមចុះក្រោម និង
- មានសន្និធិ(ស្តុក)ឧស្ម័នអិលភីជីជាក់ស្តែងសរុបចាប់ពី ១០១ (មួយរយមួយ) គីឡូក្រាម ដល់ ៥០.០០០ (ប្រាំម៉ឺន) គីឡូក្រាម។

ខ- ចំពោះប្រេងរំអិល ដែល៖

- ប្រើកំប៉ុង ឬ ធុងដែលមានចំណុះប្រេងរំអិលចាប់ពី ២០០ លីត្រ ចុះក្រោម និង
- មានសន្និធិ(ស្តុក)ប្រេងរំអិលជាក់ស្តែងសរុបចាប់ពី ២០១ (ពីររយមួយ) លីត្រ ដល់ ១៥០.០០០ (ដប់ប្រាំម៉ឺន) លីត្រ។

**ប្រការ៤.-**

នីតិបុគ្គលដែលមានបំណងលក់ឧស្ម័នអិលភីជីកំប៉ុងនិង/ឬធុង ឬដែលមានបំណងលក់និងប្តូរប្រេងរំអិលក្នុងកំប៉ុងឬធុង ដែលមានមធ្យោបាយផ្ទុកនិងកម្រិតសន្និធិជាក់ស្តែងសរុបដូចខាងក្រោម **ត្រូវមានអាជ្ញាបណ្ណសន្និធិពីក្រសួងរ៉ែនិងថាមពល** ៖

ក- ចំពោះឧស្ម័នអិលភីជី ដែល៖

- ប្រើកំប៉ុង ឬ ធុងដែលមានចំណុះឧស្ម័នអិលភីជីចាប់ពី ៤៨ គីឡូក្រាមចុះក្រោម និង
- មានសន្និធិ(ស្តុក)ឧស្ម័នអិលភីជីជាក់ស្តែងសរុបលើសពី ៥០.០០០ (ប្រាំម៉ឺន) គីឡូក្រាម។

ខ- ចំពោះប្រេងរំអិល ដែល៖

- ប្រើកំប៉ុង ឬ ធុងដែលមានចំណុះប្រេងរំអិលចាប់ពី ២០០ លីត្រចុះក្រោម និង
- មានសន្និធិ(ស្តុក)ប្រេងរំអិលជាក់ស្តែងសរុបលើសពី ១៥០.០០០ (ដប់ប្រាំម៉ឺន) លីត្រ។

**ប្រការ៥.-**

បុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុងដើម្បីលក់ ឬលិខិត

អនុញ្ញាតសន្និធិប្រេងរំអិលក្នុងកំប៉ុងឬធុងដើម្បីលក់និងប្តូរដល់យានយន្ត ដូចមានចែងក្នុងប្រការ៣នៃប្រកាសនេះ ត្រូវធ្វើការទំនាក់ទំនង ដើម្បីទទួលបានពាក្យស្នើសុំ ឬព័ត៌មានបន្ថែម និងដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយស្របតាមការកំណត់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងសន្និធិនោះស្ថិតនៅ និងត្រូវអនុវត្តតាមសេចក្តីណែនាំស្តីពីការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែ ថាមពល និងប្រេងកាត របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ៦.-**

នីតិបុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណសន្និធិឧស្ម័នអិលភីក្នុងកំប៉ុងឬធុងដើម្បីលក់ ឬអាជ្ញាបណ្ណសន្និធិប្រេងរំអិលក្នុងកំប៉ុងឬធុងដើម្បីលក់និងប្តូរដល់យានយន្ត ស្របតាមប្រការ ៤ នៃប្រកាសនេះ អាចធ្វើការទំនាក់ទំនង ដើម្បីទទួលបានពាក្យស្នើសុំ ឬ ព័ត៌មានបន្ថែម តាមរយៈ៖

ក. លេខាធិការដ្ឋានច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ឬ

ខ. អគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពលពល ឬ

គ. គេហទំព័រអគ្គនាយកដ្ឋានប្រេងកាតដែលមានអាសយដ្ឋាន www.mme.gov.kh/gdp.php។

**ប្រការ៧.-**

អ្នកស្នើសុំអាជ្ញាបណ្ណសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុងដើម្បីលក់ ឬអាជ្ញាបណ្ណសន្និធិប្រេងរំអិលក្នុងកំប៉ុងឬធុងដើម្បីលក់និងប្តូរដល់យានយន្ត ស្របតាមប្រការ ៤ នៃប្រកាសនេះ ត្រូវបំពេញពាក្យស្នើសុំមួយច្បាប់តាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៨.-**

ពាក្យស្នើសុំទាំងអស់ ស្របតាមប្រការ ៤ នៃប្រកាសនេះ ត្រូវដាក់នៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល នៅរៀងរាល់ថ្ងៃធ្វើការនិងម៉ោងធ្វើការ។

មន្ត្រីដែលទទួលពាក្យស្នើសុំនៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ភាពពេញលេញនៃពាក្យស្នើសុំនីមួយៗ រួមទាំងសំណុំឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមានភាពពេញលេញ មន្ត្រីទទួលពាក្យត្រូវចេញសលាកបត្រទទួលពាក្យជូនអ្នកដាក់ពាក្យស្នើសុំតាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ។

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារមិនពេញលេញ មន្ត្រីទទួលពាក្យត្រូវបដិសេធពាក្យស្នើសុំ ហើយណែនាំឱ្យអ្នកដាក់ពាក្យបំពេញបន្ថែមតាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។



៥

## ជំពូកទី ៣
## ការពិនិត្យ និងសម្រេចលើពាក្យស្នើសុំ

**ប្រការ៩.-**

អគ្គនាយកដ្ឋានប្រេងកាត មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារស្នើសុំ។ នីតិវិធីនៃការពិនិត្យ និងផ្តល់យោបល់នេះ មានដូចតទៅ៖

ក. ពិនិត្យរាល់ឯកសារ តាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់ និងបទប្បញ្ញត្តិបច្ចេកទេសសុវត្ថិភាពសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬដើម្បីលក់និងប្តូរដល់យានយន្ត

ខ. ក្រុមមន្ត្រីជំនាញត្រូវចុះពិនិត្យទីតាំងស្នើសុំជាក់ស្តែងតាមការចាំបាច់ ដើម្បីធ្វើកំណត់ហេតុចុះត្រួតពិនិត្យ

គ. រៀបចំរបាយការណ៍ និងកំណត់បង្ហាញជូនរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ពិនិត្យ និងសម្រេច។

**ប្រការ១០.-**

អគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល មានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារស្នើសុំ។

**ប្រការ១១.-**

បន្ទាប់ពីទទួលបានមតិយោបល់ពីអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល ថ្នាក់ដឹកនាំ និងរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល មានរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីសម្រេច ៖

ក. ឯកភាពតាមសំណើ ឬ

ខ. ឯកភាពតាមសំណើដោយមានលក្ខខណ្ឌ ឬ

គ. ស្នើឲ្យបំភ្លឺបន្ថែម ឬ តម្រូវឲ្យបុគ្គលស្នើសុំធ្វើការកែសម្រួលបំពេញបន្ថែម ឬ

ឃ. ធ្វើការបដិសេធចំពោះពាក្យស្នើសុំ ដោយមានមូលហេតុនៃការសម្រេចជាលាយលក្ខណ៍អក្សរ។

## ជំពូកទី ៤
## សុពលភាពនៃអាជ្ញាបណ្ណសន្និធិ

**ប្រការ១២.-**

អាជ្ញាបណ្ណសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងឬធុងដើម្បីលក់ ឬអាជ្ញាបណ្ណសន្និធិប្រេងរំអិលក្នុងកំប៉ុង

ឬធុងដើម្បីលក់និងប្តូរដល់យានយន្ត មានសុពលភាព ១០ (ដប់) ឆ្នាំ។ ម្ចាស់ទីតាំងសន្និធិត្រូវមកដាក់ពាក្យស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណសន្និធិ ក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ មុនពេលផុតកំណត់សុពលភាព នៅច្រកចេញ-ចូលតែមួយនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ ១៣.-**

អ្នកស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណសន្និធិ ត្រូវបំពេញពាក្យស្នើសុំមួយច្បាប់តាមទម្រង់លេខ **០០១ លអបស** កំណត់ដោយក្រសួងរ៉ែនិងថាមពល។ ចំពោះនីតិវិធីនៃការដាក់ពាក្យ ការពិនិត្យ និងសម្រេចនឹងត្រូវអនុវត្តដូចប្រការ ៨ ប្រការ៩ ប្រការ១០ និងប្រការ១១ នៃប្រកាសនេះ។

## ជំពូកទី ៥
## ការប្តូរម្ចាស់ទីតាំងសន្និធិ

**ប្រការ១៤.-**

ក្នុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណសន្និធិ ម្ចាស់ទីតាំងសន្និធិអាចផ្ទេរទីតាំងសន្និធិទៅឱ្យម្ចាស់ផ្សេងបាន ប៉ុន្តែម្ចាស់ទីតាំងសន្និធិ ត្រូវទទួលការឯកភាពពីក្រសួងរ៉ែនិងថាមពល ជាមុន។

**ប្រការ១៥.-**

អ្នកស្នើសុំធ្វើការប្តូរម្ចាស់ស្ថានីយ ត្រូវបំពេញពាក្យស្នើសុំមួយច្បាប់តាមទម្រង់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

ចំពោះនីតិវិធីនៃការដាក់ពាក្យ ការពិនិត្យ និងសម្រេច នឹងត្រូវអនុវត្តដូចប្រការ៨ ប្រការ៩ ប្រការ១០ និងប្រការ១១ នៃប្រកាសនេះ។

## ជំពូកទី ៦
## ការបង់កម្រៃសេវាកម្ម

**ប្រការ១៦.-**

ម្ចាស់ទីតាំងសន្និធិ ត្រូវបង់កម្រៃសេវាកម្មចំពោះការពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណសន្និធិ ឬផ្ទេរម្ចាស់ទីតាំង តាមការកំណត់នៅក្នុងប្រកាសរួមរវាងក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



៥

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**ប្រការ១៧..**

អាជ្ញាបណ្ណដែលបានចេញមុនប្រកាសនេះចូលជាធរមានត្រូវបន្តមានសុពលភាពរហូតដល់ចប់សុពលភាព។ ការស្នើសុំអាជ្ញាបណ្ណសន្និធិថ្មី ត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដូចមានចែងក្នុងប្រកាសនេះ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ១៨..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវបានទុកជានិរាករណ៍។

**ប្រការ១៩..**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដែលទទួលបានការប្រគល់មុខងារ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៣កើត ខែស្រាពណ៍ឆ្នាំជូត ទោស័កព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ សីហា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល** ហ.

ស៊ុយ សែម

**ចម្លងជូន:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ១៩ "ដើម្បីអនុវត្ត"
- រាជកិច្ច និងឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ................ចុះថ្ងៃទី...............ខែ................ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់ និងសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់និងប្តូរដល់យានយន្ត**

# ពាក្យស្នើសុំអាជ្ញាបណ្ណសន្និធិ ឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់ ឬ ប្រេងរំអិលក្នុងកំប៉ុង និង/ឬធុងដើម្បីលក់និងប្តូរដល់យានយន្ត

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់ទីតាំងសន្និធិ ឬ ប្រធានក្រុមហ៊ុន។

---

**១- អំពីបុគ្គលស្នើសុំ**

តួនាទី និងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន៖

☐ ប្រធានក្រុមហ៊ុន

☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន (សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង)

នាមករណ៍ក្រុមហ៊ុន ៖ ______________________ លេខចុះបញ្ជីពាណិជ្ជកម្ម : ______________

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ : ______________________________

លេខទូរស័ព្ទទំនាក់ទំនង : ______________________ អ៊ីម៉ែល : ______________

**២- អំពីគម្រោងសន្និធិ**

**២.១- ប្រភេទអាជីវកម្ម**

☐ សន្និធិឧស្ម័នអិលភីជី (LPG) ក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់

☐ សន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់និងប្តូរដល់យានយន្ត

**២.២- ព័ត៌មានអំពីទីតាំងសន្និធិ**

ឈ្មោះ ឬ ស្លាកយីហោទីតាំងសន្និធិ : ______________________________

អាសយដ្ឋានទីតាំងសន្និធិ : ______________________________

______________________________

______________________________

ទំហំផ្ទៃដីសរុប - ម៉ែត្រក្រឡា : ______________ ប្រវែងក្បាលដី (ម៉ែត្រ) ________ ប្រវែងជម្រៅដី(ម៉ែត្រ) ________

និយាមការ: រយៈបណ្តោយ : ______________________ រយៈទទឹង: ______________

ព្រំដីទីតាំងសន្និធិប៉ែកខាងជើង៖ ______________________________

ព្រំដីទីតាំងសន្និធិប៉ែកខាងត្បូង៖ ______________________________

ព្រំដីទីតាំងសន្និធិប៉ែកខាងលិច៖ ______________________________

ព្រំដីទីតាំងសន្និធិប៉ែកខាងកើត៖ ______________________________

**២.៣- បរិមាណសន្និធិ**

☐ សរុបសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់ ចំណុះ: ______________ គីឡូក្រាម

☐ សរុបសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់និងប្តូរ ចំណុះ: ______________ លីត្រ

៣- **ឯកសារភ្ជាប់មកជាមួយ**:

- ☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន ១ ច្បាប់
- ☐ លិខិតប្រគល់សិទ្ធិជាតំណាង (ក្នុងករណីអ្នកស្នើសុំធ្វើជាតំណាងឱ្យក្រុមហ៊ុន) ចំនួន ១ ច្បាប់
- ☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ក្នុងករណីអ្នកស្នើសុំធ្វើជាតំណាងឱ្យក្រុមហ៊ុន) ចំនួន ១ ច្បាប់
- ☐ ផែនទីបង្ហាញទីតាំងសន្និធិដែលត្រូវបង្កើត ចំនួន ១ ច្បាប់
- ☐ គំនូសប្លង់បច្ចេកទេសរៀបចំសុវត្ថិភាពទីតាំងសន្និធិ ចំនួន ១ ច្បាប់

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។

ថ្ងៃ...................... ខែ...................ឆ្នាំ............ ព.ស........................

............................ ថ្ងៃទី............ខែ................. ឆ្នាំ ...............

**ហត្ថលេខា និងឈ្មោះបុគ្គលស្នើសុំ**

សម្រាប់មន្ត្រីទទួលពាក្យ

ឈ្មោះមន្ត្រី៖.........................................

មូលវិចារ៖.............................................

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ................ចុះថ្ងៃទី...............ខែ.................ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់ និងសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់និងប្តូរដល់យានយន្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរ៉ែ និងថាមពល**
**អគ្គនាយកដ្ឋាន**................
បង្កាន់ដៃលេខ៖....................

**បង្កាន់ដៃទទួលពាក្យស្នើសុំ**
**(ទម្រង់ បទ០០១)**

ប្រភេទពាក្យស្នើសុំ...........................................................................................

បានទទួលសំណុំឯកសារលេខ ..................... ពីលោក/លោកស្រី.......................................... កាន់អត្តសញ្ញាណប័ណ្ណលេខ................................. ☐ ម្ចាស់សំណុំឯកសារ ☐ អ្នកទទួលសិទ្ធិកាន់ឯកសារស្នើសុំ។

ថ្ងៃទី.................... ខែ.........ឆ្នាំ............ ព.ស............
រាជធានីភ្នំពេញ ថ្ងៃទី........ខែ ......... ឆ្នាំ .........
អ្នកពិនិត្យ

បានឃើញ និងឯកភាព
ថ្ងៃទី.................... ខែ.........ឆ្នាំ............ ព.ស............
រាជធានីភ្នំពេញ ថ្ងៃទី........ខែ ......... ឆ្នាំ .........
ប្រធានច្រកចេញចូលតែមួយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរ៉ែ និងថាមពល**
**អគ្គនាយកដ្ឋាន**.............
លេខ៖..............................

## ជម្រាបជូន

**លោក/លោកស្រី** .......................................

សំណុំឯកសារនៃពាក្យស្នើសុំលិខិតអនុញ្ញាតសន្និធិ.................................... របស់លោក/លោកស្រី មិនទាន់ពេញលេញតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងរ៉ែ និងថាមពល នៅឡើយទេ។ សូមបំពេញបន្ថែមនូវឯកសារដូចខាងក្រោម៖

- ☐ ពាក្យស្នើសុំអាជ្ញាបណ្ណសន្និធិ — ០១ ច្បាប់
- ☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម — ០១ ច្បាប់
- ☐ លិខិតប្រគល់សិទ្ធិជាតំណាង (បើអ្នកស្នើសុំជាតំណាងឱ្យក្រុមហ៊ុន) — ០១ ច្បាប់
- ☐ ច្បាប់ថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (តំណាងឱ្យក្រុមហ៊ុន) — ០១ ច្បាប់
- ☐ ផែនទីបង្ហាញទីតាំងសន្និធិដែលត្រូវបង្កើត — ០១ ច្បាប់
- ☐ គំនូសប្លង់បច្ចេកទេសរៀបចំសុវត្ថិភាពទីតាំងសន្និធិ — ០១ ច្បាប់

ថ្ងៃទី..................... ខែ.........ឆ្នាំ............. ព.ស.............
រាជធានីភ្នំពេញ ថ្ងៃទី........ខែ ......... ឆ្នាំ .........
អ្នកពិនិត្យ

បានឃើញ និងឯកភាព
ថ្ងៃទី..................... ខែ.........ឆ្នាំ............. ព.ស.............
រាជធានីភ្នំពេញ ថ្ងៃទី........ខែ ......... ឆ្នាំ .........
ប្រធានច្រកចេញចូលតែមួយ

## ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ................ចុះថ្ងៃទី...............ខែ................ឆ្នាំ២០២០ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពសន្និធិឧស្ម័នអិលភីជីក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់ និងសន្និធិប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុង ដើម្បីលក់និងប្តូរដល់យានយន្ត

# ពាក្យសុំប្តូរម្ចាស់ទីតាំងសន្និធិឧស្ម័នអិលភីជីកំប៉ុងនិង/ឬធុង ឬប្រេងរំអិល

រាល់ព័ត៌មានខាងក្រោមត្រូវបំពេញដោយម្ចាស់ទីតាំងសន្និធិ ឬ ប្រធានក្រុមហ៊ុន។

---

**១- អំពីអ្នកស្នើសុំ**

តួនាទីនិងមុខងាររបស់អ្នកស្នើសុំក្នុងក្រុមហ៊ុន ៖ ☐ ប្រធានក្រុមហ៊ុន ☐ តំណាងស្របច្បាប់របស់ក្រុមហ៊ុន(សូមភ្ជាប់លិខិតប្រគល់សិទ្ធិជាតំណាង )

នាមករណ៍ក្រុមហ៊ុន ៖ ____________________ លេខចុះបញ្ជីពាណិជ្ជកម្ម : ____________

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ : ____________________

លេខទូរស័ព្ទទំនាក់ទំនង : ____________________ អ៊ីម៉ែល (E-mail) : ____________

**២- អំពីការផ្ទេរ ម្ចាស់ទីតាំងសន្និធិ**

**២.១- ប្រភេទទីតាំងសន្និធិ**

☐ លក់ឧស្ម័នអិលភីជី (LPG) ក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់

☐ លក់និងប្តូរប្រេងរំអិលក្នុងកំប៉ុងនិង/ឬធុងដើម្បីលក់និងប្តូរដល់យានយន្ត

**២.២ អំពីម្ចាស់ថ្មី**

នាមករណ៍ក្រុមហ៊ុន ៖ ____________________ លេខចុះបញ្ជីពាណិជ្ជកម្ម : ____________

អាសយដ្ឋានស្នាក់ការអចិន្ត្រៃយ៍ : ____________________

លេខទូរស័ព្ទទំនាក់ទំនង : ____________________ អ៊ីម៉ែល (E-mail) : ____________

**៣- ឯកសារភ្ជាប់មកជាមួយ**

☐ ច្បាប់ចម្លងលក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ក្រុមហ៊ុនថ្មី) ចំនួន ១ ច្បាប់

☐ លិខិតប្រគល់សិទ្ធិជាតំណាង (តំណាងឱ្យក្រុមហ៊ុនថ្មី) ចំនួន ១ ច្បាប់

☐ ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (តំណាងឱ្យក្រុមហ៊ុនថ្មី) ចំនួន ១ ច្បាប់

☐ ច្បាប់ថតចម្លងកិច្ចសន្យាលក់-ទិញស្ថានីយ ឬ លិខិតផ្ទេរស្ថានីយ រវាងម្ចាស់មុន និងម្ចាស់ថ្មី ចំនួន ១ ច្បាប់

☐ អាជ្ញាបណ្ណសន្និធិ និងប្រកាសស្តីពីលក្ខខណ្ឌដែលក្រសួងរ៉ែនិងថាមពលបានផ្តល់ជូន

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលបានបំពេញក្នុងពាក្យស្នើសុំនេះ និងក្នុងឯកសារភ្ជាប់មកជាមួយទាំងអស់ដូចមានយោងខាងលើ ពិតជាត្រឹមត្រូវ និងពិតប្រាកដ។

ថ្ងៃទី...................... ខែ.................ឆ្នាំ............ ព.ស.........................

............................ ថ្ងៃទី............ខែ................ ឆ្នាំ ...............

**ហត្ថលេខា និងឈ្មោះអ្នកស្នើសុំ**

សម្រាប់មន្ត្រីទទួលពាក្យ៖..........................................